# ប្រកាសអន្តរក្រសួង
# ស្តីពី
# បែបបទ និងនីតិវិធីនៃ
# ការផាកពិន័យចំពោះម្ចាស់ ឬ
# អ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ក្រសួងមហាផ្ទៃ
លេខ ១៦១ សហវ.ប្រក.អខ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## បែបបទ និងនីតិវិធីនៃការដាក់ពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៥៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលបានកំណត់ក្នុងមាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ត្រូវអនុវត្តដូចខាងក្រោម ៖

១- ផាកពិន័យជាប្រាក់ចំនួន ៤០០.០០០(បួនសែន)រៀល ក្នុងករណីធ្វេសប្រហែសខកខានមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ រួមមាន៖
   - មិនបានផ្តល់ប្លង់ប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ដល់អាជ្ញាធរមានសមត្ថកិច្ចតាមការស្នើសុំ។
   - មិនបានថែរក្សាឱ្យបានល្អត់ចត់នូវគុណភាពប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅ និង/ឬបរិវេណនៃទីតាំងរស់នៅប្រមូលផ្តុំ ឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស។
   - មិនបានអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការកែលម្អប្រព័ន្ធការពារសន្តិសុខ។

២- ផាកពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល សម្រាប់ជនបរទេសម្នាក់ ក្នុងករណីមានចេតនាលាក់បាំង និងអនុញ្ញាតឱ្យជនបរទេសនោះ ដែលចូលមកព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

**ប្រការ២.-**

ការអនុវត្តការផាកពិន័យដូចមានចែងនៅក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវប្រគល់ភារកិច្ចជូនមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

**ប្រការ៣.-**

មន្ត្រីនគរបាលដែលមានសមត្ថកិច្ចផាកពិន័យ ត្រូវចេញបង្កាន់ដៃផាកពិន័យចំនួនមួយច្បាប់ប្រគល់ជូនទៅបុគ្គលដែលត្រូវទទួលរងការផាកពិន័យ ទៅតាមករណីដូចមានចែងក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។ ទម្រង់គំរូបង្កាន់ដៃផាកពិន័យ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៤.-**

បុគ្គលដែលទទួលរងការផាកពិន័យ ត្រូវទៅបង់ប្រាក់ពិន័យនៅការិយាល័យគណនេយ្យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្តសាមី ឬផ្ទេរទឹកប្រាក់ពិន័យចូលក្នុងគណនីធនាគារដែលបានកំណត់ក្នុងបង្កាន់ដៃផាកពិន័យក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ។

ករណីទទួលប្រាក់ពិន័យដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ មន្ត្រីមុខការនៃការិយាល័យគណនេយ្យត្រូវចេញបង្កាន់ដៃបង់ប្រាក់ចំនួនមួយច្បាប់ប្រគល់ជូនទៅអ្នកបង់ប្រាក់ ដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីមានការយឺតយ៉ាវ ឬមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដែលបានកំណត់ នោះបុគ្គលដែលទទួលរងការផាកពិន័យនឹងត្រូវទទួលរងការផាកពិន័យចំនួន ២% បន្ថែមទៀត លើប្រាក់ផាកពិន័យដើម។

ក្នុងករណីបុគ្គលដែលទទួលរងការផាកពិន័យ មានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ នោះមន្ត្រីមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីចាត់ការទៅតាមនីតិវិធីនៃច្បាប់។

**ប្រការ៥ ._**

ជារៀងរាល់ខែ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវរួសរាន់បង់ប្រាក់ចំណូលដែលប្រមូលបានពីការផាកពិន័យ ទៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ ស្របតាមនីតិវិធីជាធរមាន ដើម្បីធ្វើការបែងចែក និងចាត់ចែងបង់ចំណូលចូលថវិកាជាតិឱ្យបានទាន់ពេលវេលា ស្របតាមគោលការណ៍ដែលបានកំណត់។

**ប្រការ៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ៣៦១......សហវ.ប្រក.អទច ចុះថ្ងៃទី១៥... ខែកុម្ភៈ ឆ្នាំ២០២៦
ស្តីពីបែបបទ និងនីតិវិធីនៃការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
អគ្គស្នងការដ្ឋាននគរបាលជាតិ
ស្នងការដ្ឋាននគរបាល..........
លេខ................................

## បង្កាន់ដៃផាកពិន័យ

យើង........................................... អត្តលេខ.................... ទូរសព្ទលេខ.............................. ជាមន្ត្រីនគរបាលបម្រើការងារនៅ............................................ បានត្រួតពិនិត្យលើទីតាំងរស់នៅប្រមូលផ្តុំមួយកន្លែង ជាប្រភេទ ............................. ដែលមានអាសយដ្ឋានលេខ......... ផ្លូវ....... ភូមិ.................. ឃុំ/សង្កាត់.................... ក្រុង/ស្រុក/ខណ្ឌ............................ រាជធានី/ខេត្ត................................ ដែលមានម្ចាស់ ឬអ្នកគ្រប់គ្រងឈ្មោះ................................. ភេទ......... ជនជាតិ............................ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ................................ ស្នាក់នៅអាសយដ្ឋានផ្ទះលេខ......... ផ្លូវ............ ភូមិ........................ ឃុំ/សង្កាត់............................ ក្រុង/ស្រុក/ខណ្ឌ..................................... រាជធានី/ខេត្ត.................................... ទូរសព្ទលេខ.................................បានប្រព្រឹត្តល្មើសនឹងមាត្រា............ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ត្រូវទទួលរងការផាកពិន័យចំនួន ...............................(...............................................) រៀល។

សូមអញ្ជើញទៅបង់ប្រាក់ផាកពិន័យនៅការិយាល័យគណនេយ្យនៃស្នងការដ្ឋាននគរបាល.............................. ឬផ្ទេរទឹកប្រាក់ពិន័យចូលគណនីឈ្មោះ............................. លេខគណនី.................... នៅធនាគារ............................។

**បញ្ជាក់៖**
- ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំដែលបានប្រព្រឹត្តអំពើល្មើស ត្រូវបង់ ឬផ្ទេរទឹកប្រាក់ផាកពិន័យក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យនេះ។
- ក្នុងករណីមានការយឺតយ៉ាវ ឬមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នឹងត្រូវទទួលរងការផាកពិន័យចំនួន ២% បន្ថែមទៀត លើប្រាក់ផាកពិន័យដើម។
- ក្នុងករណីបុគ្គលដែលទទួលរងការផាកពិន័យ មានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ នោះមន្ត្រីមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីចាត់ការទៅតាមនីតិវិធីនៃច្បាប់។
- បង្កាន់ដៃផាកពិន័យនេះ ជាប្រភេទបង្កាន់ដៃប្រើសម្រាប់ដាក់បន្ទុកផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលទទួលរងការផាកពិន័យប៉ុណ្ណោះ មិនមែនជាប្រភេទបង្កាន់ដៃដែលបញ្ជាក់ថាបានបង់ ឬបានទទួលប្រាក់ផាកពិន័យនោះទេ។៚

ធ្វើនៅ............................ ថ្ងៃទី....... ខែ............ ឆ្នាំ២០.....

**ស្នាមមេដៃស្តាំ**
**ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ**

**ហត្ថលេខាមន្ត្រីនគរបាល**